០១១- 05 JAN 2011

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : ៤៧៥៤...... សក.

រាជធានីភ្នំពេញ. ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០..

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ: 016
ថ្ងៃទី 04 ខែ 01 ឆ្នាំ 2010
ម៉ោង 15 45

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ✓

**កម្មវត្ថុ:** របាយការណ៍ស្តីពីពិធីសម្ពោធបើកការដ្ឋានសាងសង់កំណាត់ផ្លូវលេខ២១៣ ពីទីរួមស្រុករវៀង ទៅកាន់ស្ពានកំពង់ពុទ្រា ក្នុងខេត្តព្រះវិហារ ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស សូមអនុញ្ញាតគោរពរាយការណ៍ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា: នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ រូបខ្ញុំផ្ទាល់រួមទាំងថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះទៅសម្ពោធបើកការដ្ឋានសាងសង់ផ្លូវចាក់កៅស៊ូ (DBST) កំណាត់ផ្លូវប្រវែង ១៨គ.ម នៃផ្លូវលេខ២១៣ ដោយគិតចាប់ពីទីរួមស្រុករវៀង ទៅកាន់ស្ពានកំពង់ពុទ្រា ក្នុងខេត្តព្រះវិហារ ។ កំណាត់ផ្លូវនេះ ត្រូវបានចាប់ផ្តើមសាងសង់នៅក្នុងខែកញ្ញា ឆ្នាំ២០១០ ក្រោមឥណទានរបស់ធនាគារពិភពលោក និងថវិកាបដិភាគ របស់រាជរដ្ឋាភិបាល (១០ ភាគរយ) ហើយគ្រោងនឹងបញ្ចប់នៅក្នុងខែឧសភា ឆ្នាំ២០១១ ដោយប្រើប្រាស់ថវិកាចំនួន ៣.៣៧៨.៤០៨,៤៤ ដុល្លា អាមេរិក ។

ជាកិច្ចចាប់ផ្តើមនៅក្នុងពិធី ខ្ញុំបាទបានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខរបស់ប្រមុខរាជរដ្ឋាភិបាល ដែលមានសម្តេចទាំងបីជាប្រធាន ទៅកាន់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋានសរុបចំនួន៦០០នាក់ និងបានលើកឡើងអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធទូទាំងប្រទេស ជាពិសេសបណ្តាញផ្លូវថ្នល់ ។ ខ្ញុំក៏បានលើកឡើង និង ថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍នានា ទាំងក្នុង និង ក្រៅប្រទេស ដែលតែងតែផ្តល់កិច្ចសហប្រតិបត្តិការល្អក្នុងការអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់ក្នុងប្រទេសកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បន្ថែមទៀតថា : - ផ្លូវលេខ២១៣ មានប្រវែងសរុបចំនួន ៧៩,១៣៧ គ.ម គិតចាប់ពីភ្នំដែក



មហាវិថី ព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២

រហូតដល់ទីរួមស្រុកថែប ។ កាលពីដើមឡើយ ផ្លូវនេះជាផ្លូវដីក្រហេងក្រហូង ពិបាកធ្វើដំណើរ និងមិនអាចធ្វើដំណើរបានក្នុងរដូវវស្សា ជាពិសេសកំណាត់ផ្លូវប្រវែង៤២,៦៧៧ គ.ម ពីស្ពានកំពង់ពុទ្រារហូតដល់ទីរួមស្រុកថែប។ នៅឆ្នាំ២០០៥ គម្រោងហេដ្ឋារចនាសម្ព័ន្ធខេត្ត និងជនបទ (PRIP) ក្រោមឥណទានរបស់ធនាគារពិភពលោក បានសាងសង់ផ្លូវប្រវែង១៨,៥០ គ.ម ពីភ្នំដែករហូតដល់ទីរួមស្រុករវៀង ។ ក្នុងឆ្នាំ២០១០នេះ គំរោង(PRIP) បានបន្តសាងសង់ផ្លូវប្រវែង ១៨ គ.ម បន្ថែមទៀត ពីទីរួមស្រុករវៀងទៅកាន់ស្ពានកំពង់ពុទ្រា ។ ដូចនេះបន្ទាប់ពីបញ្ចប់ការសាងសង់កំណាត់ផ្លូវប្រវែង១៨ គ.ម នេះ ប្រវែងផ្លូវសរុប ៣៦,៥០ គ.ម នឹងត្រូវបានសាងសង់ដោយចាក់ក្រាលកៅស៊ូពីរជាន់ ប្រភេទ (DBST) ។ ជាមួយគ្នានេះផងដែរ នៅដើមឆ្នាំ២០១០នេះ ក្រសួងបានសាងសង់ផ្លូវដីគ្រួសក្រហមបានប្រវែង ២៩ គ.ម ហើយនឹងបន្តសាងសង់ផ្លូវ ១០ គ.ម បន្ថែមទៀត ក្នុងឆ្នាំ២០១១ នៅលើកំណាត់ផ្លូវ ពីស្ពានកំពង់ពុទ្រាដល់ទីរួមស្រុកថែប ។

មុននឹងបិទនូវកម្មវិធីសម្ពោធបើកការដ្ឋានកំណាត់ផ្លូវលេខ២១៣ខាងលើនេះ ខ្ញុំបាទបានលើកឡើងនូវការយកចិត្តទុកដាក់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងលោកជំទាវ លើសុវត្ថិភាពចរាចរណ៍ និងធ្វើការក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋអោយយកចិត្តទុកដាក់ខ្ពស់ក្នុងការធ្វើដំណើរ ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់ជាយថាហេតុ ដែលអាចកើតមានឡើង ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីពយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ ។

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**